ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៩៣ សហវ - ឋយក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## ការធ្វើបច្ចុប្បន្នកម្មសមាសភាពគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេស សម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៨ /១០៥៥ ចុះ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បកចុះ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បកចុះ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុពីឆ្នាំ ២០០៦-២០១៥ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ៨៦៩ សហវ.ចុះ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញលិខិតរបស់ក្រសួងយុត្តិធម៌ លេខ ៣៨៥.កយ.រប/១១ ចុះថ្ងៃទី ២ខែ មីនា ឆ្នាំ ២០១១ ស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមក្នុងគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០

Downloaded from http://www.khmerlaws.com

St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញលិខិតរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លេខ ៤៧៥ ស.អ.យ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញដើម្បីចូលរួមក្នុងគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០
- បានឃើញលិខិតរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ ២០២ កប ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពីការចាត់បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមក្នុងគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០
- បានឃើញលិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ១១៤៣ព.ណបល ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការធ្វើបច្ចុប្បន្នកម្មសមាសភាពគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០
- បានឃើញលិខិតរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ១.០១១.០៦៧ល.ស ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពីសំណើសុំបញ្ចូលសមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីជំនាញធនាគារជាតិនៃកម្ពុជាក្នុងគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសរបស់រាជរដ្ឋាភិបាលសម្រាប់ធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០
- បានឃើញលិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ ៣០៣/១១ ក.អ.ក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពីសំណើធ្វើបច្ចុប្បន្នកម្មគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១១-២០២០
- បានឃើញលិខិតរបស់គណៈកម្មការមូលបត្រកម្ពុជាលេខ ០៨២ គ.ម.ក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ស្តីពីការធ្វើបច្ចុប្បន្នកម្មគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១១-២០២០
- បានឃើញលិខិតរបស់នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការលេខ ០០៣ សហវ.វ.ស ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការធ្វើបច្ចុប្បន្នកម្មគណៈកម្មាធិការដឹកនាំ និងក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ២០១១-២០២០ ។

# សម្រេច

**ប្រការ ១ :**

ធ្វើបច្ចុប្បន្នកម្មសមាសភាពគណៈកម្មាធិការដឹកនាំ (Steering Committee) និងក្រុមការងារបច្ចេកទេស (Technical Working Group) សម្រាប់អនុវត្តការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (Financial Sector Development) ដែលមានសមាសភាពដូចខាងក្រោម ÷

Downloaded from http://www.khmerlaws.com

**ក. សមាសភាពថ្មីរបស់គណៈកម្មាធិការដឹកនាំ** ( Steering Committee):

| | | |
|---|---|---|
| ១- ឯកឧត្តម **ជា ចាន់តូ** | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម **ជា ប៉េងឈាង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ហង់ ជួន ណារ៉ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម **មុត ខៀវ** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥- ឯកឧត្តម **ម៉ៅ ថូរ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- ឯកឧត្តម **ឃួន រ៉ានីន** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៧- ឯកឧត្តម **ស៊ី សន្តិសិទ្ធ** | អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៨- ឯកឧត្តម **រស់ ស៊ីលវ៉ា** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- ឯកឧត្តម **ជា ធុន្នី** | អគ្គលេខាធិការរងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០- ឯកឧត្តម **ហេង សួរ** | អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១១- ឯកឧត្តម **ម៉ិញ ឋានកុសល** | អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ១២- ឯកឧត្តម **ចំនួ មនោ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ១៣- ឯកឧត្តម **កៅ ថាច** | អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |

**ខ. សមាសភាពថ្មីរបស់ក្រុមការងារបច្ចេកទេស** ( Technical Working Group):

| | | |
|---|---|---|
| ១- ឯកឧត្តម **រស់ ស៊ីលវ៉ា** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ផាន់ ហួរ** | អគ្គលេខាធិការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម **កៅ ថាច** | អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **ម៉ី វ៉ាន់** | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- លោកស្រី **ខួន សុខា** | អគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៦- លោកស្រី **ជា ស៊ីរី** | អគ្គនាយករងត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៧- លោក **សារំណាត វឌ្ឍនា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

Downloaded from http://www.khmerlaws.com

៨- លោក ថៃ សតា ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចធនាគារជាតិនៃកម្ពុជា សមាជិក

៩- លោក ម៉ែន ធីរុទ្ធ ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០- លោក ឡិម តារារិទ្ធិ ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួងពាណិជ្ជកម្ម សមាជិក

១១- លោក តាំង សុជាតិ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
ក្រសួងពាណិជ្ជកម្ម សមាជិក

១២- លោក ចន ណារិទ្ធ ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ
នៃគណៈកម្មការមូលបត្រកម្ពុជា សមាជិក

១៣- លោក សុខ ដារ៉ា ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ
នៃគណៈកម្មការមូលបត្រកម្ពុជា សមាជិក

១៤- លោក ឈុន សម្បត្តិ ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ
នៃគណៈកម្មការមូលបត្រកម្ពុជា សមាជិក

១៥- លោក ហាំង តុលា ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ
នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៦- លោក ឆាន់ ស៊ីណា ប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ នៃក្រសួងយុត្តិធម៌ សមាជិក

១៧- លោក ឆន ពិសិដ្ឋ អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៨- លោក ប៊ូ ចំនួតីរ អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៩- លោក រស់ តីរុណា អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

២០- លោក ជូ ទណ្ណះ អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

២១- លោក សុខ សុគេន អនុប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្ត
នៃគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

២២- លោក ជួរ រតនៈ នាយកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

២៣- លោក ហែម បូរ៉ា នាយកបេឡាជាតិអតីតយុទ្ធជន
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

២៤- លោក ចេង គីមហ៊ាង ប្រធានការិយាល័យគណនេយ្យ នៃក្រសួងយុត្តិធម៌ សមាជិក

Downloaded from http://www.khmerlaws.com

២៥- លោក **លាង ពិសិដ្ឋ** ប្រធានការិយាល័យគ្រប់គ្រងថវិកា នៃក្រសួងយុត្តិធម៌ សមាជិក

២៦- លោក **ឃាក់ ម៉ុន្តារិទ្ធ** អនុប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

**ប្រការ ២:**

**គណៈកម្មាធិការដឹកនាំ** ( Steering Committee) **មានភារកិច្ចដូចតទៅ ÷**

- សម្របសម្រួលចំពោះជំនួយឧបត្ថម្ភដែលម្ចាស់ជំនួយបានផ្តល់សំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- តាមដាន និងជំរុញការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ពិនិត្យ និងផ្តល់ការណែនាំ ស្តីពីគោលនយោបាយហិរញ្ញវត្ថុ និងថវិកាសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- រៀបចំយុទ្ធសាស្ត្រផែនការសកម្មភាព និងយន្តការគៀងគរប្រភពធនធានព្រមទាំងការបែងចែកធនធានហិរញ្ញវត្ថុសំរាប់វិស័យនោះ
- ពិនិត្យ និងពង្រឹងប្រព័ន្ធរៀបចំផែនការថវិកា និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ដោយសម្របសម្រួលផែនការទាំងនោះទៅនឹងផែនការកសាងសមត្ថភាពក្នុងវិស័យអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ធ្វើការចរចា និងចុះហត្ថលេខាលើអនុស្សារណៈនានាពាក់ព័ន្ធជាមួយជំនួយបច្ចេកទេស និងឥណទានជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើវិស័យនេះ
- ធ្វើរបាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជូនរាជរដ្ឋាភិបាលអំពីការវិវត្តន៍នៃដំណើរការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។

**ប្រការ ៣:**

**ក្រុមការងារបច្ចេកទេស** ( Technical Working Group) **មានភារកិច្ចដូចតទៅ ÷**

- បំពេញការងារតាមការណែនាំរបស់គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ធ្វើការងារជាមួយក្រុមជំនួយបច្ចេកទេស ដើម្បីជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្នុងកិច្ចព្រមព្រៀងឥណទានឱ្យទទួលជោគជ័យ
- ជំនួយការឱ្យគណៈកម្មធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុក្នុងការតាមដាននិងត្រួតពិនិត្យនូវការអនុវត្តការងារប្រចាំថ្ងៃរបស់ក្រុមប្រតិបត្តិការប្រចាំសាមីស្ថាប័ននីមួយៗ
- សំរបសំរួលឱ្យមានការឯកភាពគ្នារវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើរាល់បញ្ហាដែលពាក់ព័ន្ធទៅនឹង :
  - ហិរញ្ញប្បទានសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
  - ការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និង
  - ការត្រួតពិនិត្យលើការអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងប្រើប្រាស់
- ធ្វើរបាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុអំពីការវិវត្តន៍នៃផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ

Downloaded from http://www.khmerlaws.com

**ប្រការ ៤:**

ក្រសួងស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវបង្កើតក្រុមប្រតិបត្តិរបស់ខ្លួនដើម្បីអនុវត្តគំរោងប្រចាំថ្ងៃរបស់ក្រសួង ឬ ស្ថាប័នសាមី ដែលមានចែងក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងជាចំណុចសំរាប់ធ្វើទំនាក់ទំនងអន្តរស្ថាប័នលើការងារនេះ ។

**ប្រការ ៥:**

គណៈកម្មាធិការដឹកនាំមានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៦:**

ក្រុមការងារបច្ចេកទេសមានលេខាធិការដ្ឋាននៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៧:**

សមាជិកនៃគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសទាំងអស់ ត្រូវចូលរួមប្រជុំពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុតាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ ៨:**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចប្រការ ០១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ

**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

**« ដើម្បីជូនជ្រាប »**
- ដូចប្រការ ០១ និងប្រការ ០៨
- ស្ថាប័នពាក់ព័ន្ធ

**« ដើម្បីអនុវត្ត »**
- ឯកសារ- កាលប្បវត្តិ

Downloaded from http://www.khmerlaws.com